# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 233

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងកែលម្អផ្លូវជនបទ ដំណាក់កាលទី២

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/15

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/20

៣. ចំណាយគម្រោងសរុប $192,710,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងអភិវឌ្ឍន៍ជនបទ

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ផ្លូវដែលបានកែលម្អរួច នឹងផ្តល់ដល់ខេត្តក្រីក្រជនបទនូវសុវត្ថិភាព ចំណាយតិចក្នុងការធ្វើដំណើរទៅកាន់ទីផ្សារ និងសេវាសង្គមផ្សេងៗទៀត និងអាចធ្វើដំណើរ បានគ្រប់រដូវកាល។ កាត់បន្ថយគំលាតរវាងតំបន់ជនបទ និងទីក្រុង

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

អភិវឌ្ឍន៍ជនបទ

Other

Other

Other

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ត្បូងឃ្មុំ , កំពង់ស្ពឺ, កំពង់ធំ, បាត់ដំបង, សៀមរាប, បន្ទាយមានជ័យ, ពោធិ៍សាត់, កំពង់ឆ្នាំង, កំពង់ចាម, តាកែវ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គោលដៅរបស់គម្រោងគឺធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ទីផ្សារ និងសេវាសង្គមផ្សេងៗ ងាយស្រួលស្វែងរកការងារធ្វើ និងផ្តោតផងដែរ ទៅលើសុវត្ថិភាពសង្គម ភាពធន់នឹងអាកាស ធាតុ និងប្រសិទ្ធភាពចំណាយលើការកែលម្អបណ្តាញផ្លូវជនបទដែលអាចឲ្យប្រជាពលរដ្ឋធ្វើដំណើរបានគ្រប់រដូវកាល នៅក្នុងតំបន់ដែលមានវិសាលភាពកសិកម្មខ្ពស់ នៃខេត្តគោលដៅគម្រោងទាំង ១០។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

មានលទ្ធផលគន្លឹះសំខាន់ៗចំនួន ០៥ ក្នុងគម្រោងនេះគឺ៖ (១) កែលម្អផ្លូវជនបទ (២)ការគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវជនបទ (៣) កម្មវិធីសុវត្ថិភាពតាមផ្លូវថ្នល់ និងសហគមន៍ (៤)គាំទ្រដល់ការគ្រប់គ្រងគម្រោង និង(៥) កែលម្អផ្លូវតភ្ជាប់ទៅកាន់កោះនៅទន្លេមេគង្គ

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោងនឹងកែលម្អផ្លូវជនបទប្រវែង ១,២០០ គីឡូម៉ែត្រ ក្នុងខេត្តចំនួន ១០ គឺ ខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ស្ពឺ សៀមរាប ឧត្តរមានជ័យ និងខេត្តតាកែវ។ ផ្លូវដែលបានកែលម្អរួច នឹងផ្តល់ដល់ខេត្តក្រីក្រជនបទនូវសុវត្ថិភាព ចំណាយតិចក្នុងការធ្វើដំណើរទៅកាន់ទីផ្សារ និងសេវាសង្គមផ្សេងៗទៀត និងអាចធ្វើដំណើរ បានគ្រប់រដូវកាល។ គម្រោងក៏នឹងគាំទ្រដល់ក្រសួងអភិវឌ្ឍន៍ជនបទ នូវកម្មវិធីថែទាំផ្លូវប្រកបដោយនិរន្តរភាព ផងដែរ

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

ប្រជាជនរស់នៅក្នុងខេត្តគោលដៅ និងអ្នកធ្វើដំណើរឆ្លងកាត់ផ្សេងៗទៀត

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? មាន

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? ត្រូវបានបញ្ចប់

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

ផ្នែកបរិស្ថានរបស់គម្រោងគឺត្រូវបានផ្តល់តាមគម្រោងដែលបានស្នើ ដូចជា កែលម្អលើផ្លូវដែលមានស្រាប់ មិនពង្រីក ត្រួផ្លូវជាដើម។ គម្រោងសាងសង់ផ្លូវមួយចំនួនក្នុងខេត្តបាត់ដំបង និងពោធិសាត់ គឺមានទីតាំងក្នុងតំបន់អភិរក្ស ជីវៈចម្រុះបឹងទន្លេសាប។ សកម្មភាពមួយចំនួនទៀត ស្ថិតក្រោមលទ្ធផលនៃការកែលម្អការផ្សារភ្ជាប់តំបន់ កោះទន្លេមេគង្គ ដូចជាការសាងសង់ទំនប់ទឹកចំនួន ១០ កន្លែងនៅជិតទន្លេមេគង្គ។ គ្មានសកម្មភាពរបស់ គម្រោងណាមួយចំនួនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់តំបន់ជិតខាង ហើយក្រសួងអភិវឌ្ឍន៍ជនបទក៏ មិនមាន ការជំទាស់ពីស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម និងគណៈកម្មការ ជាតិទន្លេមេគង្គ ក្នុងការអនុវត្តសកម្មភាពរបស់គម្រោង។ ការត្រួតពិនិត្យបឋមលើបរិស្ថាន ដូចជាលទ្ធផលនៃការសិក្សាផ្នែកបរិស្ថាន និងគម្រោងប្លង់ការងាររបស់គម្រោងការភ្ជាប់តំបន់ទន្លេមេគង្គ ត្រូវបានរៀបចំឡើងស្របតាមគោលនយោបាលសុវត្ថិភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

រាជរដ្ឋាភិបាល តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ នឹងប្រាកដថា ការវិភាគយេនឌ័រត្រូវបានអនុវត្តបានពេញលេញ និងធានាថាគ្រប់សកម្មភាពរបស់គម្រោងត្រូវបានរៀបចំ និងអនុវត្តតាមគោលនយោបាយស្តីពីយេនឌ័រ និងការអភិវឌ្ឍន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ វិធានការណ៍ផ្សេងៗនិងត្រូវបានរាប់បញ្ចូលដូចជា ការងារនឹងត្រូវប្រើប្រាស់កំលាំងពលកម្មតាមលក្ខណៈបច្ចេកទេសដែលអាចប្រើបាន ។ការងារដែលប្រើកំលាំងពលកម្មមិនមានជំនាញ ត្រូវមានស្ត្រីយ៉ាងហោចណាស់ ២០% ចូលរួមធ្វើការងារនេះ។ ស្ត្រី និងបុរសដែលធ្វើការងារមិនមានជំនាញដូចគ្នា ត្រូវទទួលបានប្រាក់ឧបត្ថម្ភដូចគ្នា។ ជម្រេលជើងទេផ្លូវត្រូវធ្វើឲ្យមានលក្ខណៈងាយស្រួលសម្រាប់ស្ត្រី ឬក្មេងស្រី ធ្វើដំណើរ។ គ្រប់ទិន្នន័យសេដ្ឋកិច្ចសង្គមត្រូវបែងចែកតាមភេទ។ មន្ត្រីសេដ្ឋកិច្ចសង្គម អ្នកម៉ៅការ មន្ត្រីសម្របសម្រួលគម្រោងថ្នាក់ខេត្តដែលពាក់ព័ន្ធនឹងគម្រោងត្រូវបានបណ្តុះបណ្តាលស្តីពីយេនឌ័រ និងការងារ សង្គមផ្សេងៗទៀត។ ការកែលម្អផ្លូវនៅលើកោះនៃទន្លេមេគង្គដែលប្រើកំលាំងកម្មករគ្មាន ជំនាញក្នុងការសាងសង់ ផ្លូវបេតុង ត្រូវមានកម្មករជាស្ត្រីចំនួន ៤០%។ សមាសភាគយេនឌ័ររបស់គម្រោងគឺ "ប្រសិទ្ធភាពយេនឌ័រ" ។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

ក្រសួងអភិវឌ្ឍន៍ជនបទ មានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងនេះ

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

បានជ្រើសរើសទីប្រឹក្សាគ្រោងប្លង់លំអិត និងត្រួតពិនិត្យបច្ចេកទេសក្នុងការសាងសង់ផ្លូវ
ទីប្រឹក្សាគ្រោងការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងអនុវត្ត និងទីប្រឹក្សាកម្មវិធីបង្ការការឆ្លងមេរោគអេដស៍ និងជួញដូរមនុស្ស។
គម្រោងមិនមានការពន្យាពេលក្នុងការអនុវត្តទេ

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

- ធនាគារអភិវឌ្ឍន៍អាស៊ី
- រដ្ឋាភិបាលអូស្រ្តាលី
- សាធារណរដ្ឋកូរ៉េ
- មូលនិធិអភិវឌ្ឍន៍ណរឌីក
- សាធារណរដ្ឋបារាំង

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 23,694.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 23,694.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទិញសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 23,694.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 0.0 | 0.0 | 23,694.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Asian Development Bank | 0.0 | 0.0 | 23,694.0 | 0.0 | 0.0 | 0.0 | 0.0 | |
| Other | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| Republic of Korea | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 23,694.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: